អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន
## ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹងសាទុក្ខចូលរួមក្នុងព្រឹត្តិការណ៍សវនាការប្រកាស សាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០១

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរការីនានា នឹងរៀបចំកម្មវិធីសម្រាប់ការចូលរួមរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកធ្វើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ចំនួន ៩០ នាក់ ចូលរួមក្នុងព្រឹត្តិការណ៍សវនាការប្រកាសសាលដីកាលើបណ្តឹងសាទុក្ខប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច។

អង្គជំនុំជម្រះតុលាការកំពូលនៃ អ.វ.ត.ក នឹងប្រកាសសាលដីកាលើបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០១ ប្រឆាំងនឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច នៅថ្ងៃសុក្រ ទី៣ ខែកុម្ភៈ ឆ្នាំ ២០១២ វេលាម៉ោង ១០ ព្រឹក។ បន្ទាប់ពីចូលរួមស្តាប់ការប្រកាសសាលដីកា និងចូលរួមសកម្មភាពផ្សេងៗនៅ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹងសាទុក្ខទាំងអស់ នឹងត្រូវបានសម្របសម្រួលជួបប្រជុំគ្នា ដើម្បីធ្វើពិធីបុណ្យបង្សុកូល សម្រាប់ឧទ្ទិសកុសលដល់ជនរងគ្រោះ ដែលបានស្លាប់ ពិគ្រោះផ្លូវចិត្តជាមួយអ្នកចិត្តសាស្ត្រ និងជួបជាមួយមេធាវីរបស់ខ្លួនដើម្បីពិភាក្សាលើការរំពឹងទុកនានា នៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក វេលាម៉ោង ២ និង ៣០ នាទីរសៀល។

នៅថ្ងៃព្រហស្បតិ៍ ទី២ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ២ រសៀល មួយថ្ងៃមុនការចូលរួមការប្រកាសសាលដីកានេះ ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកប្តឹងសាទុក្ខ នឹងត្រូវបានសម្របសម្រួលដើម្បីជួបប្រជុំគ្នាជាមួយមេធាវីរបស់ខ្លួននៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដើម្បីរំលឹកប្រវត្តិនៃសំណុំរឿង ០០១។

---

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**

អ៊ឹម សុភា, ប្រធានកម្មវិធីផ្សព្វផ្សាយនៃអង្គភាពគាំពារជនរងគ្រោះ

ទូរស័ព្ទចល័ត: ០៧៧ ៧៧៧ ៣៦៧, អ៊ីម៉ែល: im.sophea@eccc.gov.kh